# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ០១១ MIH / 2016

## ប្រកាស
## ស្តីពី
## នីតិវិធីក្នុងការអនុវត្តពិន័យអន្តរការណ៍ តាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់អំពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ស្តីពីប្រកាសឱ្យប្រើច្បាប់ ស្តីពីការវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញបទបញ្ជារាជរដ្ឋាភិបាលលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## សម្រេច

**ប្រការ១ .–**

ប្រកាសនេះ មានគោលបំណងកំណត់នូវនីតិវិធីអនុវត្តពិន័យអន្តរការណ៍ជាប្រាក់លើបទល្មើស របស់ម្ចាស់រោងចក្រ និងសិប្បកម្ម ដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com

**ប្រការ២ .-**

ប្រកាសនេះអនុវត្តពិន័យអន្តរការណ៍ ចំពោះម្ចាស់រោងចក្រនិងសិប្បកម្មទាំងអស់ អនុលោមតាមមាត្រា៥៥ នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៣ .-**

- ពិន័យអន្តរការណ៍ គឺជាទោសទណ្ឌទាំងឡាយណាដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០រៀល (ប្រាំរយពាន់រៀល) ទៅ ១០.០០០.០០០រៀល (ដប់លានរៀល) ដែលអនុវត្តដោយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជំនួសយន្តការរបស់តុលាការ។
- មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម គឺជាមន្ត្រីដែលបានទទួលការតែងតាំងដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម។
- គណៈកម្មការពិន័យអន្តរការណ៍ គឺជាគណៈកម្មការដែលបានទទួលការតែងតាំងដោយ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។
- លិខិតពិន័យជាប្រាក់ គឺជាលិខិតចេញដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដល់ម្ចាស់រោងចក្រ និងសិប្បកម្ម ដែលបញ្ជាក់ពីកំហុសដែលបានប្រព្រឹត្តនិងទឹកប្រាក់ត្រូវពិន័យ។

**ប្រការ៤ .-**

គណៈកម្មការពិន័យអន្តរការណ៍ ត្រូវចេញលិខិតពិន័យដល់ម្ចាស់រោងចក្រ និងសិប្បកម្ម ដែលបានប្រព្រឹត្តល្មើសដូចមានចែងក្នុងមាត្រា១១ មាត្រា១៣ មាត្រា១៤ មាត្រា១៥ មាត្រា១៦ មាត្រា១៧ មាត្រា១៨ មាត្រា២៣ មាត្រា២៦ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៤១ ហើយត្រូវផ្តន្ទាទោសពិន័យជាប្រាក់តាម មាត្រា៤៣ មាត្រា៤៤ និងមាត្រា៤៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ដូចមាននៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៥ .-**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម អាចបញ្ជូនលិខិតពិន័យទៅគេហដ្ឋាន ឬរោងចក្រ និងសិប្បកម្ម ដែលត្រូវទទួលលិខិតពិន័យជាប្រាក់នេះដោយផ្ទាល់ ឬតាមសំបុត្រអនុសិដ្ឋដោយមានចុះហត្ថលេខាបានទទួល។ ក្នុងករណីដែលម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រនោះ បដិសេធមិនព្រមទទួលលិខិតពិន័យរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសិទ្ធិអញ្ជើញអាជ្ញាធរ ឬភ្នាក់ងារនគរបាលឱ្យចូលរួមជាមួយខ្លួនដើម្បីធ្វើជាសាក្សី។ បើម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រ មិនស្ថិតក្នុងគេហដ្ឋាន ឬក្នុងរោងចក្រនោះ លិខិតពិន័យអាចត្រូវបានប្រគល់ទៅឱ្យជនណាម្នាក់ ដែលមានការពាក់ព័ន្ធតាមផ្លូវច្បាប់ជាមួយនឹងម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រនោះ។

**ប្រការ៦ .-**

ប្រសិនបើលិខិតពិន័យជាប្រាក់គ្មានអ្នកទទួលជំនួស ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបិទលិខិតពិន័យជាប្រាក់នោះនៅច្រកចូល ឬមាត់ទ្វាររោងចក្រ ឬនៅគេហដ្ឋានរបស់ម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រនោះ ដោយមានវត្តមានរបស់អាជ្ញាធរ ឬភ្នាក់ងារនគរបាលជាសាក្សី។ ក្រោយពីប្រតិបត្តិការដូចបានចែងក្នុងវាក្យខណ្ឌខាងលើ លិខិតពិន័យជាប្រាក់ត្រូវបានចាត់ទុកថាបានទទួលដោយម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រ។

**ប្រការ៧ .-**

ម្ចាស់រោងចក្រ និងសិប្បកម្ម ត្រូវមកបង់ប្រាក់ពិន័យអន្តរការណ៍តាមការកំណត់របស់គណៈកម្មការពិន័យអន្តរការណ៍នៅការិយាល័យច្រកចេញចូលតែមួយនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម យ៉ាងយូរ ១៥ថ្ងៃ ចាប់ពីថ្ងៃទទួល

បានលិខិត។ ក្នុងករណីម្ចាស់រោងចក្រ និងសិប្បកម្ម ខកខានមិនបានបង់ប្រាក់ពិន័យតាមកាលកំណត់ខាងលើនេះត្រូវទទួលការពិន័យពីរភាគរយក្នុងមួយថ្ងៃលើចំនួនទឹកប្រាក់ដែលត្រូវបង់ពិន័យ។ ប្រាក់ពិន័យនេះត្រូវគណនាតាមរូបមន្តការប្រាក់សមាស។

**ប្រការ៨ .-**

ចំពោះម្ចាស់រោងចក្រ និងសិប្បកម្ម ណាដែលបានប្រព្រឹត្តបទល្មើសដដែលហើយពុំរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរ លើទឹកប្រាក់ពិន័យដែលត្រូវបង់។

**ប្រការ៩ .-**

ក្នុងករណីម្ចាស់រោងចក្រ និងសិប្បកម្ម រឹងរូសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រោយរយៈពេល ៩០ ថ្ងៃចាប់ពីថ្ងៃទទួលលិខិតពិន័យ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

**ប្រការ១០ .-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ និងគ្រប់អង្គភាពស្ថាប័នសាធារណៈវិស័យឯកជនដែលមានការពាក់ព័ន្ធអង្គភាពចំណុះក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សមាគមរោងចក្រកាត់ដេរសម្លៀកបំពាក់នៅកម្ពុជា
- គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត
- ដូចប្រការ ១០ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធ

### ស្ថានទម្ងន់ទោសស្តីពីកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម ដោយពុំបានស្នើសុំការយល់ព្រមពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវ ព្រមទាំងរយៈពេលកែតម្រូវ

| បទល្មើស | រយៈពេលប្រព្រឹត្តបទល្មើសនៃសកម្មភាពរោងចក្រ និងសិប្បកម្ម | | | | ផ្សេងៗ |
|---|---|---|---|---|---|
| | ចាប់ពី ៦ខែ | ចាប់ពី ១២ខែ | ចាប់ពី ១៨ខែ | ចាប់ពី ២៤ខែ ឡើងទៅ | |
| ក្នុងករណីបង្កើតសិប្បកម្ម ដែលតម្រូវឲ្យស្នើចុះបញ្ជី ដោយពុំបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅមូលដ្ឋាន និងពុំបានធ្វើការចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម សិប្បកម្ម រាជធានី ខេត្ត ដែលខ្លួនបានបោះទីតាំង ក្នុងរយៈពេល០៧ថ្ងៃ ក្រោយថ្ងៃដំណើរការ (មាត្រា៤៣)។ | ៥០០ ០០០ រៀល | ១ ០០០ ០០០ រៀល | ១ ៥០០ ០០០ រៀល | ២ ៥០០ ០០០ រៀល | ក្នុងករណីរឹងរូស មិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវកសាងសំណុំរឿង បញ្ជូនទៅតុលាការ។ |
| ក្នុងករណី បង្កើតប្រភេទសិប្បកម្ម ដែលចែងដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយគ្មានការអនុញ្ញាត (មាត្រា៤៣)។ | ១ ០០០ ០០០ រៀល | ២ ០០០ ០០០ រៀល | ៣ ០០០ ០០០ រៀល | ៥ ០០០ ០០០ រៀល | |
| ក្នុងករណី ពង្រីក ឬបង្កើតសាខា ឬផ្លាស់ប្តូរទីតាំងរោងចក្រ ពុំមានលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម (មាត្រា៤៤)។ | ១ ០០០ ០០០ រៀល | ៥ ០០០ ០០០ រៀល | ៨ ០០០ ០០០ រៀល | ១០ ០០០ ០០០ រៀល | |
| ក្នុងករណី ប្តូរម្ចាស់រោងចក្រ ម្ចាស់រោងចក្រថ្មី ពុំបានធ្វើការសុំទទួល ស្គាល់ជាម្ចាស់រោងចក្រពីក្រសួង | ១ ០០០ ០០០ រៀល | ៥ ០០០ ០០០ រៀល | ៨ ០០០ ០០០ រៀល | ១០ ០០០ ០០០ រៀល | |

| | | | | | |
|---|---|---|---|---|---|
| ឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល ១០ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលខ្លួនបានទទួលសិទ្ធិជាម្ចាស់រោងចក្រថ្មី (មាត្រា ៤៤)។ | | | | | |
| ក្នុងករណី ម្ចាស់រោងចក្រទទួលមរណភាព ឬអសមត្ថភាព តាមផ្លូវច្បាប់ អ្នកទទួលសិទ្ធិគ្រប់គ្រងបន្តពុំបានធ្វើពាក្យសុំការទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល ៤៥ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលម្ចាស់រោងចក្រដើមទទួលមរណៈភាព ឬបាត់បង់សមត្ថភាពតាមផ្លូវច្បាប់ (មាត្រា ៤៤)។ | ១ ០០០ ០០០ រៀល | ៥ ០០០ ០០០ រៀល | ៨ ០០០ ០០០ រៀល | ១០ ០០០ ០០០ រៀល | |
| ក្នុងករណី ម្ចាស់រោងចក្រ ពុំបានជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេលមួយខែ មុនថ្ងៃដែលរោងចក្របញ្ឈប់ដំណើរការជាស្ថាពរ (មាត្រា ៤៤)។ | ១ ០០០ ០០០ រៀល | ៥ ០០០ ០០០ រៀល | ៨ ០០០ ០០០ រៀល | ១០ ០០០ ០០០ រៀល | |
| ក្នុងករណី ម្ចាស់រោងចក្រពុំបានតាំងបង្ហាញប្រកាសបង្កើតរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ (មាត្រា ៤៤)។ | ១ ០០០ ០០០ រៀល | ៥ ០០០ ០០០ រៀល | ៨ ០០០ ០០០ រៀល | ១០ ០០០ ០០០ រៀល | |
| ក្នុងករណី បាត់បង់ប្រកាសបង្កើតរោងចក្រ ឬ/និងលិខិតអនុញ្ញាតទាំងឡាយ ម្ចាស់រោងចក្រពុំបានធ្វើពាក្យសុំប្រកាស ឬលិខិតជំនួសមួយទៀត មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃបាត់បង់ (មាត្រា ៤៤)។ | ១ ០០០ ០០០ រៀល | ៥ ០០០ ០០០ រៀល | ៨ ០០០ ០០០ រៀល | ១០ ០០០ ០០០ រៀល | |

| | | | | | |
|---|---|---|---|---|---|
| ក្នុងករណី រោងចក្រពុំមានផ្លាកឈ្មោះ ពុំបានលើកបង្ហាញផ្លាកឈ្មោះរោងចក្រនៅកន្លែងងាយមើលឃើញខាងមុខរោងចក្រ ហើយផ្លាកឈ្មោះរោងចក្រពុំបានសរសេរជាអក្សរខ្មែរ មានទំហំធំជាង និងនៅលើអក្សរផ្សេងៗទៀត (មាត្រា ៤៤)។ | ១ ០០០ ០០០ រៀល | ៥ ០០០ ០០០ រៀល | ៨ ០០០ ០០០ រៀល | ១០ ០០០ ០០០ រៀល | |
| ក្នុងករណី ផ្លាស់ប្តូរឈ្មោះរោងចក្រ ដោយគ្មានការយល់ព្រមពី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម (មាត្រា ៤៤)។ | ១ ០០០ ០០០ រៀល | ៥ ០០០ ០០០ រៀល | ៨ ០០០ ០០០ រៀល | ១០ ០០០ ០០០ រៀល | |
| ក្នុងករណី មានឧប្បត្តិហេតុ ឬ គ្រោះថ្នាក់នៅក្នុងរោងចក្រ ដែលបណ្តាលឲ្យរោងចក្រផ្អាកដំណើរការទាំងស្រុងលើសពី ៧ថ្ងៃ ហើយម្ចាស់រោងចក្រពុំបានជូនដំណឹងជាលាយលក្ខណ៍អក្សរមក ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីថ្ងៃកើតហេតុ (មាត្រា ៤៤)។ | ១ ០០០ ០០០ រៀល | ៥ ០០០ ០០០ រៀល | ៨ ០០០ ០០០ រៀល | ១០ ០០០ ០០០ រៀល | |
| ក្នុងករណី រោងចក្រមិនមានប្រព័ន្ធបង្ការអគ្គីភ័យ ដែលរួមមាន:<br>• ប្រព័ន្ធប្រកាសភាពអាសន្ន និងមធ្យោបាយសម្រាប់ ពន្លត់អគ្គីភ័យ<br>• សញ្ញាប្រយ័ត្នអគ្គីភ័យ នៅកន្លែងដែលចាំបាច់<br>• ទ្វារសង្គ្រោះយ៉ាងតិចបំផុតមានចំនួនពីរ នៅតាមជាន់នីមួយៗ<br>• ផ្លូវសង្គ្រោះ សម្រាប់រថយន្តពន្លត់អគ្គីភ័យ | ១ ០០០ ០០០ រៀល | ៥ ០០០ ០០០ រៀល | ៨ ០០០ ០០០ រៀល | ១០ ០០០ ០០០ រៀល | |

| | | | | | |
|---|---|---|---|---|---|
| • មធ្យោបាយរំដោះខ្លួនផ្សេងៗទៀត<br>• ប្លង់បំព្រួញសម្រាប់ជម្លៀសខ្លួនពេលមានអាសន្ន។ (មាត្រា ៤៦) | | | | | |
| ក្នុងករណី ម៉ាស៊ីន ឬផ្នែកនៃម៉ាស៊ីនដែលអាចបង្កឲ្យមានគ្រោះថ្នាក់ជាយថាហេតុ មិនមានគម្រប ឬ ឧបករណ៍ការពារ (មាត្រា ៤៦)។ | ១ ០០០ ០០០ រៀល | ៥ ០០០ ០០០ រៀល | ៨ ០០០ ០០០ រៀល | ១០ ០០០ ០០០ រៀល | |
| ក្នុងករណី មិនមានសញ្ញាបង្ហាញប្រាប់ប្រយ័ត្នគ្រោះថ្នាក់ ឬបំរាមនៅ កន្លែងដែលមានគ្រោះថ្នាក់ (មាត្រា ៤៦)។ | | | | | |
| ក្នុងករណី ប្រើប្រាស់ជាតិផ្ទុះ គ្រឿងឆេះ ជាតិពុលគីមីគ្រោះថ្នាក់ ឬឧស្ម័នក្នុងផលិតកម្ម មិនបានប្រតិបត្តិតាមលក្ខណៈបច្ចេកទេសដែលធានាបាននូវសុវត្ថិភាព (មាត្រា ៤៦)។ | ១ ០០០ ០០០ រៀល | ៥ ០០០ ០០០ រៀល | ៨ ០០០ ០០០ រៀល | ១០ ០០០ ០០០ រៀល | |
| ក្នុងករណី ឡចំហាយ ប្រព័ន្ធប្រើប្រាស់ចំហាយ ឧបករណ៍ ឬធុង ដែលប្រើសម្ពាធខ្ពស់ មិនមានការត្រួតពិនិត្យ និងអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម មុនពេលដំណើរការ (មាត្រា ៤៦) ។ | ១ ០០០ ០០០ រៀល | ៥ ០០០ ០០០ រៀល | ៨ ០០០ ០០០ រៀល | ១០ ០០០ ០០០ រៀល | |
| | | | | | |